មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយ ម៉ៅ យន់ ភេទស្រី អាយុ៥០ឆ្នាំ

**មុខងារសម័យខ្មែរក្រហមៈ «កងចល័ត»**

**សព្វថ្ងៃរស់នៅភូមិអូរគគីរកណ្តាល ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ ផាត កុសល**

**០០:៥៥:៤៥**

**២៤ទំព័រ**

កុសល : ថ្ងៃនេះថ្ងៃអី ថ្ងៃសុក្រ ២៥ ។ ភូមិនេះ ភូមិអី ភូមិអូរគគីរកណ្តាលមិនមែន?

យន : អូរគគីរកណ្តាល ។

កុសល : ឃុំអូរគគីរដដែល?

យន : ឃុំលំទង ស្រុកអន្លង់វែង ។

កុសល : ខេត្ត?

យន : ឧត្តរមានជ័យ ។

កុសល : បងឈ្មោះអីដែរ?

យន : ខ្ញុំនោះឈ្មោះ ម៉ៅ យន់ ។

កុសល : កើតថ្ងៃទីប៉ុន្មាន ខែប៉ុន្មាន ឆ្នាំណាដែរ?

យន : វាអាយុ៥០ហើយ ដឹងឆ្នាំ១៩៦០ ប៉ុនមិនដឹង៦០ប៉ុន្មាន ៦៥ ៦៦នឹងយ៉ាងមើលទៅ ព្រោះ៥០ គិតមើល ។

កុសល : អាយុ៥០?

យន : ចា៎!

កុសល : ដឹងកើតខែប៉ុន្មាន?

យន់ : កើតនៅខែពិសាខ ត្រូវនឹងថ្ងៃ៦ ។

កុសល : កើតនៅភូមិអី ឃុំ ស្រុក ខេត្ត?

យន់ : ឃុំស្រុកខេត្ត យ៉ាប់ដែរឪពុកធ្វើទាហានចិន ប៉ុនដឹងក្តីនៅកំពង់ចាម ដល់សួរស្រុកកំណើតម៉ែឪនេះ ។

កុសល ៖ ចឹងបងនៅកំពង់ចាម?

យន់ ៖ ខ្ញុំនៅតាំងពីឆ្នាំ៧០ មុនសមាហរណកម្មមក ទៅនៅតែកំពង់ចាមទាំងអស់នឹង ប៉ុនដល់ពេល ។

កុសល ៖ ស្រុកអីអត់ដឹង?

យន់ ៖ ឃុំស្រុក នៅនោះ នៅភូមិបុសខ្នុរ ស្រុកចំការលើ ដល់ខេត្តៗកំពង់ចាម អានឹងពេលយើងផ្លាច់ខ្លួនពី៧៥មក ។

កុសល ៖ ស្រុកចំការលើ?

យន់ ៖ ចាំ! ស្រុកចំការលើ ដល់ខេត្តៗកំពង់ចាម ។

កុសល ៖ ដល់ភូមិអត់ដឹង?

យន់ ៖ ភូមិធ្លក់ក្រវ៉ាន់ ។

កុសល ៖ អាស័យដ្ឋានបច្ចុប្បន្ន បងនៅណាដែរ?

យន់ ៖ អាស័យដ្ឋានសព្វថ្ងៃៗនៅភូមិអូរគគីរកណ្តាល កាលពីជំនាន់យើងឆ្នាំ៧៥នៅកំពង់ចាម ។

កុសល ៖ ពី៧៥នៅកំពង់ចាម?

យន់ ៖ ចាំ! ហើយដល់ស្រុកកំណើតម៉ែឪនៅអំពិលកន្ទឹកយើងនេះ ប៉ុនដល់ពេលមួយជំនាន់នឹងគាត់ធ្វើការរាជការ ។

កុសល ៖ ហើយបងធ្វើម៉េចបានមកដល់នេះ ពី៧៥មកដល់៧៩បងនៅកំពង់ចាម?

យន់ ៖ ចាំ! ពី៧៥ ៧៩នៅ ។

កុសល ៖ ដល់ពេលពួកយួនចូលមកយកមកត្រឡប់មកនេះ?

យន់ ៖ ចាំ! ដល់ពេលយួនមកឆ្នាំ៨២ខ្ញុំមក ។

កុសល ៖ ហេតុអីបានបងរត់មកខាងនេះ?

យន់ ៖ មួយជំនាន់នោះដែលយើងប្រជាជនដែលក្រីក្រយើងធ្វើស្រែចំការទៅ ដូចថាវាមានចោទថាចេះចុះគេតាមដានថាយើងវាមានពាក់ព័ន្ធ ខ្លាំងដែលឆ្លងកាត់ខបសត្តតាមស្រែចំការទៅ ហើយយើងអ្នកស្រុកដឹងស្រាប់ហើយ ។

កុសល ៖ ស្រដៀងឪពុកខ្ញុំដែរ?

យន់ ៖ ចាំ! ដល់គេចោទទៅ ដល់ពេលយើងភ័យភិតទៅ មានពួកខាងនឹងគេដឹកនាំយើងមក ចឹងខ្ញុំជាប់គុកអស់រយៈកាលប៉ុន្មានខែដែរនឹង ជាប់គុកនៅឃុំបុសខ្នុរ អស់រយៈកាល២អាទិត្យបានដល់ពេលចេញពីគុកវិញមក ក៏បានពួកខាងនឹង គេយកមកក៏ជាប់ទាំងបងទាំងប្អូនមកជាមួយ ។ ជាប់ដូចថាយើងធ្វើស្រែចំការចឹង ឆ្លងកាត់ ។

កុសល : បងជាប់គុក?

យន់ : ចា៎! ខ្ញុំជាប់គុកអស់រយៈកាលមួយអាទិត្យដែលនឹង គេឆែកកាត់ថាយើងដឹកស្បៀងឲ្យខ្មាំង ឲ្យ អីមួយជំនាន់នឹង តែយើងអត់ទេ ។

កុសល : ខ្ញុំសួរដូចមកឆ្លងកាត់សង្គ្រាមមកចឹង មានការប៉ះទង្គិចផ្លូវទឹកចិត្តម៉េចខ្លះ បងមានដែលចេះ តែគិតនឹកឃើញដល់ព្រឹត្តិការណ៍គួរឲ្យខ្លាចដែលអត់?

យន់ : កាលពីយើងជំនាន់នេះនឹង ខ្លាចភិតភ័យនឹងបានប្ដូរផ្ដាច់ចេញពីគុកមក យកមកនេះហើយ មានពាក្យឃោសនា ខ្ញុំថាចេះចុះ ដល់តាមពិតទៅ វាអត់មានហេតុផលទេ វាមានពាក្យ ដែលញុះញង់ពីក្រៅៗមកពីអ្នកដឹកនាំ ។

កុសល : បាទ! ចឹងចេះតែនឹកឃើញៗខ្លាចពីសម័យណា?

យន់ : នឹកឃើញខ្លាចនោះ បើនិយាយពីរឿងសម័យតស៊ូ៧៩មក តស៊ូថាកាលនឹងយើងប្រឆាំង ជាមួយយួន ដល់ពេលក្រោយមក យើងនៅតែប្រឆាំងជាមួយយន តែយើងនៅខំមិនទាន់ ជឿជាក់ថា អ្នកណាជាគណបក្សប្រឆាំង ហើយអ្នកណាជាគំនុំគំគួនយើងអត់ទាន់ដឹងជំនាន់ នោះ ។ ដល់ពេលមកក្រោយមក យើងនៅប្រឆាំងជាមួយយួន តែមកដល់សព្វថ្ងៃយើង ចរចារត្រឹមត្រូវ ចរចាស្រួលបួលទៅដូចថាមិនដឹងថាអ្នកណាសម្លាប់អ្នកណា ក៏អត់ដឹងដែរ កាលនឹង យើងសញ្ជាតិខ្មែរដូចតែគ្នា ។

កុសល : ចឹងខ្ញុំសួរបងត្រឡប់ទៅវិញ បងនៅចាំបានអីខ្លះ មុនរបបពន្លា បងនៅចាំបានអីខ្លះដូច កាលនឹងសមាជិកគ្រួសារប៉ុន្មាននាក់?

យន់ : កាលនោះបងប្អូនខ្ញុំនៅជុំគ្នា៦នាក់ ។

កុសល : ទាំងអស់៦នាក់ បងនៅអាយុ១៥ឆ្នាំនៅឡើយ?

យន់ : ចា៎!

កុសល : ៦នាក់ ហើយនៅលីវនៅឡើយ?

យន់ : នៅលីវទាំងអស់ ។

កុសល : ចុះឪពុកម្ដាយនៅធ្វើអីដែរ ធ្វើទាហាន មុន៧៥?

យន់ : និយាយពីមុន៧៥មក ប៉ាខ្ញុំគាត់ធ្វើទាហាន គាត់ធ្វើការនៅទន្លេបិទនឹង ។

កុសល : ទាហានខាងបដិវត្តន៍?

យន់ : ហ៎! ទាហានយើងពីជំនាន់លន់ នល់ មកតាំងពីជំនាន់ឥស្សរៈមក ដល់ពេលរួចគេសម្លាប់ ចោល៧៥ អត់មានធ្វើអីទេ នៅកសិករ ប្រជាជនយើងក្រោមរបបរបស់គេទាំងអស់ ។

កុសល : ហើយកាន់សាសនាអីដែរ?

យន់ : ខ្មែរសុទ្ធសាធ អត់មានលាយអី ។

កុសល : ព្រះពុទ្ធ កាន់សាសនាព្រះពុទ្ធ?

យន់ : ចាំ!

កុសល : សញ្ជាតិក៏ខ្មែរសុទ្ធសាធ ។ មុខរបររបស់ឪពុកម្តាយ ខ្ញុំដាក់ថាធ្វើទាហានចឹងបានទេ?

យន់ : ចាំ! ព្រោះប៉ាខ្ញុំពី៧៥ គាត់ធ្វើទាហានមែននឹង ដល់ពេលក្រោយពីនឹងមករហូតទល់សព្វថ្ងៃ អត់មានធ្វើអីទេ ។

កុសល : ចុះកាល៧៥ គាត់ធ្វើអី?

យន់ : ឆ្នាំ៧៥ផ្តាច់ខ្លួនយើង១៧មករា(មេសា) នេះ គេយកទៅសម្លាប់ចោលនឹង ។

កុសល : អូ! គាត់ស្លាប់?

យន់ : ចាំ! គេយកទៅវៃចោលមួយជំនាន់យើង៧៥នឹង ១៧មេសានឹង វៃគេយកទៅខាងសួង តែប្រពន្ធកូនគេបំបែកគ្នារហូតមកបានជារស់ប្រពន្ធហើយនឹងកូន ។

កុសល : ចឹងមុនឆ្នាំ៧៥នឹង គឺថាដូចថាគ្រួសារបង យើងក្រ ឬក៏ក្របន្តួរ ឬក៏អ្នកមាន បើបងរៀបរាប់ទៅ មុន៧៥?

យន់ : កាលពីមុន៧៥វាមធ្យម ។

កុសល : កសិករមធ្យម?

យន់ : ចាំ!

កុសល : កាលនឹងបងរៀបការនៅ?

យន់ : នៅ ៧៥ ។ ខ្ញុំទើបមករៀន៩២ ខ្ញុំទើបមានគ្រួសារ៩២ ។

កុសល : អត់ទាន់មានទេ?

យន់ : ចាំ!

កុសល : ចឹងបងរស់នៅមុនសម័យ៣ឆ្នាំនឹងបងរស់នៅកំពង់ចាម?

យន់ : ចាំ!

កុសល : តំបន់ប៉ុន្មានកាលនឹង គេហៅដូច៧៥មក?

យន់ : ឆ្នាំ៧៥យើងបើស្លួងគេថា១៧មេសា ។

កុសល : ប៉ុន្តែតំបន់នៅកន្លែងកំពង់ចាមនៅក្នុងភូមិភាគអី ភូមិភាគកណ្តាល?

យន់ : ខេត្តកណ្តាលនៅខាងស្រីសន្ធរ ។

កុសល : ភូមិភាគជំនាន់ខ្មែរក្រហមគេចែក?

យន់ : ខាងនឹង គេទៅខាងគេចែងខាងជប់ខាងសួងហៅស្អីបូព៌ា ។

កុសល ៖ ភូមិភាគបូព៌ា?

យន់ ៖ ចា៎! បូព៌ាខាងកំពង់ចាមខាងនឹង ខាងទន្លេបិទគេឆ្លងកាត់ទៅខាងត្បូងឃុំវិញ នឹងបូព៌ា ។

កុសល ៖ ចឹងបងធ្វើអីដែលមុនរបបពជ្នាំ?

យន់ ៖ កាលពីមុនរបបពជ្នាំពីសង្គមចាស់ ខ្ញុំនៅក្មេងៗរកស៊ីលក់ដូរនៅផ្សារ ដែលឪពុកធ្វើការងាររាជការ ។

កុសល ៖ នៅកន្លែងបងនៅមានការរើសអើងដូចជាពូជសាសន៍អីទេ មានចាមមានអីទៅនៅកាលនឹងនៅតែកំពង់ចាម?

យន់ ៖ កំពង់ចាមមានតែវាមាន២កន្លែង វាខាងប៉មភូមិចាម ខាងរកាធំក៏ខ្ញុំពីដំនាន់ បើប៉ាខ្ញុំធ្វើការនៅខាងរកាធំខាងទន្លេបទ ខាងជើងស្ពានគីសូណានឹងមិនមានភូមិចាម ។ ដល់ពេលខ្ញុំនៅត្រើយខាងនេះ នៅកន្លែងដីដុះនឹងវាមានភូមិចាម មិនឃើញដឹកដើមចាន់វាមានភូមិ២កន្លែងនឹង ។

កុសល ៖ ចឹងបងរំលឹកឡើងវិញ ពេលថ្ងៃដែលដូចជាប្រទេសរំដោះ១៧មេសាហ្នឹង បងមានអារម្មណ៍យ៉ាងម៉េចដែរ ពេលថ្ងៃនឹង នៅចាំបានអីខ្លះ បន្ទាប់ពីនឹង បងកំពុងធ្វើអីពេលនឹង?

យន់ ៖ គ្មានពេលធ្វើអី គេកាលនឹងចងចាំបានចេញពីឆ្នាំ៧៥ ១៧មេសាមក គេជម្លៀសយើងដើររហូត គេជម្លៀសចេញពីនឹងទៅៗរកាគយៗទៅដីហែរ បកមកពីដីហែរភូមិរៀងៗទៀតអត់ស្គាល់ទៀត បានមកដល់ជប់ ជួបឪពុកខ្ញុំគេបញ្ជូនទៅនៅនឹងជប់នឹង ។ ដល់ទៅគេបញ្ជូនប្រពន្ធកូននឹងនៅកន្លែងបន្ទាយនឹង កងមួយបន្ទាយនឹងវាមិនមានប៉ុន្មានរយគ្រួសារទាហានសង្ស័យទាហាន ដល់ពេលនេះគេបំបែកប្រពន្ធកូនទៅនៅអីឃុំស្អឹគេនេះ គេហៅតាម៉ៅតាអ៊ុម ទៅបាន៧៦បានគេជម្លៀសខ្ញុំមកនៅនឹងបុសខ្នុរនឹងវិញ ពី៧៥នឹងខ្ញុំជម្លៀសនោះប៉ុនអាភូមិនោះវាហូរហែលនៅស្មើរ ប៉ុនខ្ញុំអត់ចាំ ។ ដល់គេជម្លៀសនឹងទៅ ដល់ឆ្នាំ៧៦ខែ៧ គេជម្លៀសពីនឹងមកនៅនឹងបុសខ្នុរជាប់រហូតនឹងបុសខ្នុរ ។

កុសល ៖ ហើយគេមានធ្វើបាបធ្វើអីដែរ?

យន់ ៖ មាន គេធ្វើបាប ប៉ុនខ្ញុំចេះតែគេចវេស បើម៉ែខ្ញុំគាត់ចេះចងចាំ ដូចសព្វថ្ងៃខ្ញុំនៅជាកូនក៏ភ័ន្តប្រឡំគេមកជំរិតសួរយើងដែរ យប់ឡើងគេមកតាមដានការពារដូចថាគេសួរយើងពីអតីតប្រវត្តិតស៊ូពីនោះមក យើងនាយទុនហើយក៏កសិករចឹង ។ ខ្ញុំចេះថាខ្ញុំមិនមែនទេ កូនកសិករ ឪពុករកស៊ីធាក់ស៊ីក្លូ ធាក់រឺម៉ក់ កូនដើរបេះត្រកួនប៉េះអីទៅលក់ទៅ ក៏បានវាសល់ ។ ដល់ចូលមកដល់ឆ្នាំ៧៩ មុនរំដោះនឹងអានឹងគេប្រុងថាយកទៅវៃចោលប្រល័យពូជសាសន៍

កម្ពុជាយើង ។ កាលនឹងគេមិនផ្លាស់ប្ដូរថាទុកតែប៉ុន្មានរយនាក់នឹង ហើយឈ្មោះគ្រួសារខ្ញុំ វាត្រូវទៅនឹង ទាល់ដល់ថ្ងៃ១០ ខែ៩ ឆ្នាំ៧៩(៧៨) ខែប៉ុន្មាន ។

កុសល ៖ ពេលនឹងបងនៅលីវនៅឡើង?

យន់ ៖ ខ្ញុំនៅលីវ នៅកងចល័ត ។

កុសល ៖ អាយុប៉ុន្មាន?

យន់ ៖ អានឹង១៦ ១៧ អានឹងខ្ញុំកំពុងដញ្ជូនស្រូវ ខែកត្តិក ខែមាឃយើង អាចខែ១១ ១២ មើលទៅ ។ កាលនឹងយើងមិនរំដោះបានក្នុងខែ១ ខែ២ ខែ១១ ខែ១២ ។ រំដោះបានមក ខ្ញុំកំពុងដញ្ជូនកណ្ដាប់នឹង កំពុងនាំគ្នាសប្បាយនឹង គេមកពន្យាក់អាសន្ន គេថានែក! រើយនាំគ្នាមត្រៀម តែយួនមកកាត់-ក ដាក់តែអុង នាំគ្នារត់ៗរហូតដល់អន្លាយបុសពួក បានមានពាក្យឃោសនាសាមគ្គីសង្គ្រោះជាតិ គេមកសង្គ្រោះយើងផុតពីក្រញ៉ាំដៃរបប ប៉ុល ពត ។ ដល់រត់ទៅបានចូលមក ដល់ចូលមកស្រុកវិញនឹង នៅបាន២ឆ្នាំ ៧៩, ៨០, ៨១ ចាប់ផ្ដើមចុះធ្វើចំការ ។ នឹងអង្គការមកចែកដីតាមគ្រួសារអន្លាន់ចែកគ្នា ។ ដល់ពេលយើងធ្វើការតិចទៅ កាលនឹងក៏មានថាខ្មែរនេះខ្មែរនោះ ខ្មែរក្រហមដើរឆ្លងកាត់ទៅ ដល់ទៅគេថា ចេះចុះគេចាប់យកខ្ញុំទៅដាក់គុកអស់រយៈកាល ។

កុសល ៖ ពួកយួនចាប់?

យន់ ៖ ចាំ!

កុសល ៖ ជំនាញការវៀតណាម?

យន់ ៖ ចាំ! គេថាយើងទាក់ទងជាមួយខ្មែរក្រហមយកស្បៀងយកស្ពៃ ចេះយកស្បៀងស្ពៃប្អូនតូចៗ ម៉ែចាស់ មិនដែលរកស៊ីស្ពៃ គ្មានស្ពៃនឹងបានចិញ្ចឹមខ្មែរក្រហមដល់គេចោទចឹង គេចាប់ដាក់គុក ។ ដល់គេតាមដានទៅ អត់មានទៅក៏ពួកប្អូនថ្លៃខ្ញុំនឹង ប្អូនខ្ញុំមេភូមិនឹងវាថា គួរណាស់ ឈឺចាប់ដែលបើគេយកយើងដាក់គុកអត់រឿងចឹង ។ ពួកខ្ញុំឆ្លងកាត់មែនបងឯងឈឺចាប់ទេ មិនដឹងថាម៉េចថា គេថាឥឡូវមកៗតាមគេរហូតតស៊ូក្នុងព្រៃនឹងគេអស់រយៈ ។ រហូតមកដល់ដងពេកនេះ ការឈឺចាប់ដល់ពេលគេតាមដានទៅ ដូចថាគ្នាឯងចេះតែចោទប្រកាន់គ្នាឯង ។ ប៉ុនជំនាន់ខ្ញុំនឹង វាច្រើនថាដែលយើងពាក់ព័ន្ធចឹង វាមានអ្នកជិតខាងឡូញ៉ុះញ៉ង់ ដូចថាដើរឆ្លងកាត់ចំការនឹងទៅមានអ្នកនោះថា អ! នេះវាមានទាក់ទងចេះមួយចុះមួយ វាចេះតែចោទប្រកាន់ ។ ប៉ុន្តែការឈឺចាប់នៅតែឈឺចាប់ ដែលឪពុកម្ដាយដែលគេសម្លាប់ចោលពីសម័យពាឆ្នាំ ។ ឈឺចាប់ឥតភ្លេច ទាល់តែសព្វថ្ងៃ ប៉ុនថាដល់ពេលនេះយើងរស់នៅសព្វថ្ងៃមួយជំនាន់តស៊ូក្នុងរបបប៉ុល ពតដែរ ។

កុសល : ខុសគ្នាយ៉ាងម៉េចបងពេលនឹង ពេលជំនាន់ប៉ុលពត និងក្រោយជំនាន់ប៉ុលពត បងទៅរស់នៅក្នុងព្រៃ វាខុសគ្នាយ៉ាងម៉េចដែរ?

យន់ : បើតាមមើលទៅដល់ពេលរស់នៅពីសម័យ៣ឆ្នាំមក ដែលខ្ញុំរស់នៅក្នុងពីក្នុង៨៣ ៨៤ មកទល់សព្វថ្ងៃនេះ ដល់តាមដាននឹងវាក៏នៅក្នុងរបបប៉ុលពតដែរ ។ ប៉ុនដូចជាមិនឃើញការសម្លាប់ដូចជំនាននោះ ។ បានខ្ញុំឆ្ងល់ត្រង់នេះ?

កុសល : ល្អជាង ក្រោយមកនេះល្អជាង?

យន់ : ចាំ! បានវានៅទាស់ប្រឆាំងគ្នា មួយថាយួន មួយថាខ្មែរក្រហមៗ និងចិនៗ ដល់ពេលចឹងទៅខ្ញុំវាស្តាប់អត់បាន ត្រង់ថាគេវៃខ្មែរត្រង់ខ្មែរ ប៉ុនអាមួយថាមួយយួន មួយចិន អាត្រង់នឹងមិនដឹងជាគេថាម៉េច អត់ដឹងដែរ ។

កុសល : គេឲ្យបងចូលមក បនាប់ពី៧៩នឹង បងមានតួនាទីធ្វើអីខ្លះ?

យន់ : អត់មានធ្វើអីផង ធ្វើតែស្រែ និងចំការ ។

កុសល : គេអត់មានឲ្យតួនាទីអីទេ?

យន់ : អត់មានឲ្យតួនាទីអីផង អត់ ។

កុសល : ហើយក្រោយមកម៉េចទៀតទៅ?

យន់ : ដល់ក្រោយមក ក៏អត់មានធ្វើការងាររអី នៅធ្វើតែស្រែចំការរហូត ។

កុសល : ហើយសម្រេចចិតនៅនេះតែម្តង អត់ត្រឡប់ទៅភូមិកំពង់ចាមវិញ?

យន់ : ខ្ញុំទៅៗ ទើបមក៥-៦ឆ្នាំទៅវិញ ដីទៅសួរមេភូមិគេថា ដីតែយើងចេញទៅ ក៏ចែកឲ្យគ្នាអ្នកក្រីក្រដូចមកពីនេះពីនោះអត់ គេដកចែកឡើង២-៣ជំនាន់ទៀតហើយនឹង ។ ដល់ចែកគ្រប់នេះចឹងទៅ ដល់សួរគេថាយើងអត់មានទេៗ ខ្ញុំនៅនោះអត់មានដីផ្ទះដីសម្បែងអស់ទៅ ក៏ខ្ញុំបកមកនេះវិញ ។ ខ្ញុំបានប្អូនខ្ញុំឲ្យឡើង៣០ម៉ែត្រនេះដី បើដីចំការនេះបាន២-៣ហត្ថ តែប៉ុននឹងគ្មានស្អីទៀតអត់ ។

កុសល : ចុះបងថា បងធ្លាប់ទៅណាទៅណា បានដើរចេញក្រៅប្រទេសអីដែរ?

យន់ : ខ្ញុំអត់ដែរ ។

កុសល : ចុះបងឯង គិតមើលត្រឡប់ទៅ ក្នុងរបបខ្មែរក្រហម របប៣ឆ្នាំ យើងជាជនរងគ្រោះ ឬក៏យ៉ាងម៉េច?

យន់ : ខ្ញុំចេញពីនងទៅ ។

កុសល : រឿងរបស់បងចំឡែក ព្រោះបងឯងឪពុកស្លាប់ជំនាន់ ប៉ុល ពត?

យន់ : ចាំ!

កុសល : គេសម្លាប់ ដល់ក្រោយមកចេញទៅព្រៃហាក់ដូចជាមានការប្រែប្រួលល្អជាង?

យន់ : ចា៎!

កុសល : ចឹងបងឯងយល់ថា របប ប៉ុល ពត នឹងម៉េចទៅចឹង?

យន់ : របប ប៉ុល ពត គឺរបបការដែលកាប់សម្លាប់ៗ ដល់ពេលនឹងវាដូចថាឃោសនាៗ គេថាពីមុនមក គេថាយួននឹងសម្លាប់ឃោសនាគេ ដល់យើងខំប្រឹងប្រឆាំងជាមួយយួនដើម្បីទាមទារយកទឹកដីៗ ដល់ពីក្រោយមកតាមដានមក ដែលខ្ញុំមកនៅមួយរយៈកាលកន្លងមក មុននឹងផ្តាច់ខ្លួនអស់រយៈកាលជាង១០ឆ្នាំមក ដល់តាមដានស៊ើបទៅ វាឃើញតែខ្មែរដែលវ៉ៃខ្មែរៗ

កុសល : មានឃើញតែខ្មែរ អត់មានបរទេសណាមកទេ?

យន់ : ចា៎! ដូចមិនមានឃើញ ព្រោះអានឹងឃើញជាក់ស្តែងឃើញតែខ្មែរឯង តែបើអ្នកបញ្ជាវាអត់ដឹងមានបញ្ជាមកពីណា បើខ្ញុំនៅស្ទើរដែរ វាអត់បានចុះរៀនចុះជាប់អីបានឃើញតែខ្មែរវ៉ៃខ្មែរគ្នាឯង ដូចជាក្នុងភូមិធ្លាក់ក្រវ៉ាន់ខ្ញុំជាដើម ដូចមួយសេរីគ្នាឯង១៧ ១៨ចឹងទៅក៏មានដល់នោះយើងឆ្នាំ៧៦ ៧៧គេមានស្អីគេថាភ្កុកសដីរអី ខ្សាដីរភ្កុកស ដីរខៀវម៉េចទៅណានោះ ឃើញតែខ្មែរគ្នាឯងដែរៗ ដល់ពេលដូចថាយកទៅវ៉ៃចោលចឹង ដល់យើងគេដាក់ខ្សែវ៉ៃចោលចឹង ដល់ពេលយើងរត់រួចទៅ បើសិនជាគេដើរតាមដាន ដើរតាមធ្វើការតាមបុសចេក តាមព្រៃយើងឃើញ គេចាប់បានមកគេថាយើងខ្សែខ្មាំងៗ អានឹងខ្ញុំជាក់ស្តែងឃើញចឹងមង ប៉ុនដល់ពេលខ្មាំងនឹងអត់មានទេ តែខ្មែរយើងដែលគេយកទៅវ៉ៃចោល ខ្មែរយើងចាប់វ៉ៃចោលដែរ ប៉ុនអ្នកបញ្ជាការមិនដឹងមកពីខាងណា វាអត់ដឹងនៅស្ទើរៗ

កុសល : ខ្ញុំសួរវិញធ្វើម៉េចទៅ ដូចថាបងឆ្លងកាត់មកចឹង ឪពុកស្លាប់ចឹង ធ្វើម៉េចឲ្យប្រទេសយើងមានការផ្សះផ្សាជាតិ ដែលផ្សះផ្សារវាងកុំឲ្យមានអ្នកនេះ អ្នកក្រហម ខៀវអីចឹង ថាធ្វើម៉េចឲ្យមានការផ្សះផ្សាៗ ហើយផ្សះផ្សារស់នៅឲ្យមានសន្តិភាពរហូតទៅ? កូនប៉ុន្មានបង?

យន់ : ខ្ញុំកូនសព្វថ្ងៃនៅ២ ៗ

កុសល : ចុះអានេះមួយពៅគេ?

យន់ : អានេះចៅៗ

កុសល : ចុះឥឡូវនឹងបារម្ភរឿងបញ្ហាជាមួយជនបរទេសដែល បងគាំទ្រ ដែលថាឲ្យរដ្ឋាភិបាលកាត់បន្ថយជនជាតិបរទេសនៅក្នុងតំបន់ ឥទ្ធិពលជនជាតិបរទេស?

យន់ : អានឹងគាំទ្រ ចំនុចសព្វថ្ងៃរស់ពិបាកបានថាចឹង បើសព្វថ្ងៃ ជនបរទេសដូចឃើញស្រាប់ហើយ តាមដីតាមអស់នេះមើលទៅសុទ្ធតែអត់ទេមានខ្មែរ មានសុទ្ធតែជនជាតិបរទេស

២០០, ៣០០ហិចតា ។ សព្វថ្ងៃ កំពុងប៉ះរឿងដីតំបន់ខាងខ្ញុំ ប៉ុន្មានខែមុននេះប៉ះ ។ អានឹងដល់ពេលនោះសុទ្ធតែពួកវិនិយោគទុន តែមិនដឹងគេខាងណា ។

កុសល : គេដាក់ក្រុមហ៊ុនខ្មែរមក តាមមើលតាមពិតសុទ្ធតែបរទេស?

យន់ : ចាស៎!

កុសល : ចឹងខ្ញុំសួរបងបន្ថែម ចុះពីមុនមកពេលមុន អ្នកចាស់ៗដែលនៅពីមុន ហើយឥឡូវដូចថា មានអ្នកថ្មីៗតាមបងលន់ គាត់ប្រាប់មកថាមានអ្នកថ្មីចូលមកនៅច្រើន?

យន់ : ចាស៎! ចូលច្រើន ។

កុសល : តើដូចថាការរស់នៅពីមុនមកមានការទុកចិត្តគ្នាទៅវិញទៅមកល្អទេ? ហើយខុសប្លែកម៉េច ពេលអ្នកថ្មីចូលមក?

យន់ : ដែលសព្វថ្ងៃ បើនិយាយថា ព្រោះនិយាយថា បើពីពួកអ្នកមុនៗមកនឹងដូចអត់មានរឿង ឆក់ ប្លន់គាបសង្កត់អីអត់មានទេ ។ តែមានអ្នកចំណូលមក មានតាំងពីវិនិយោគទុន មាន តាំងដូចថាវាដាក់ថ្នា សព្វថ្ងៃនឹងវាមានជាហូរហែរក្នុងតំបន់ខាងនេះ ផ្នែកមុនៗអត់មានទេ នៅមកសព្វថ្ងៃនឹងវាមាន ។ វាមានអ្នកចំណូលច្រើន វាមានអ្នកធ្វើសមាហរណកម្មនឹងក៏វា ច្រើនដែរ ។

កុសល : កាលពីមុនៗមកអត់អីទេសាមគ្គីភាពគ្នាល្អ?

យន់ : ចាស៎! សាមគ្គីភាព កាលពីមុនមកសាមគ្គី សូម្បីតែមាន់ ទា ដីធ្លី អត់មានអ្នកណាគាបសង្កត់ទេ ឯកភាពចែកគ្នាធ្វើមួយរស់ស្រួល ។ តែដល់ពេលមានវិនិយោគទុនធ្លាក់មកចឹងទៅ គាបសង្កត់ពីមួយទៅមួយសូម្បីតែព្រៃដីមួយចង្អាមក៏ទាមទារ ដូចថានាយទុក កសិករ តែគេ ។ តែអ្នកកសិករតួយ៉ាងខ្ញុំជាដើម ដីកុំតែនេះចឹង អស់រលីងអត់មានសល់ទេ នឹងមានប្អូនមានមុខមានមាត់តិចតួចផង ដើម្បីជួយបានតិច ។ សូម្បីតែដីផ្ទះនឹង ពីដើមគេមកប្រុងដាក់ទុនធ្វើផ្លូវស្អីយកកន្លែងនឹងលក់ឲ្យនាយទុនទាំងអស់ ប៉ុន្តែខ្ញុំចេះតែប្រឆាំង ខ្ញុំថាតស៊ូមួយរយៈកាល កន្លងមក សូម្បីតែម៉ាក្បែរផ្ទះដាក់ផ្លូវមិនឲ្យដាក់ សុខចិត្តសង់ផ្ទះបានផ្លូវប៉ុននឹង ទាមទារបានប៉ុននឹង ទាមទារនៅសល់ប៉ុននឹង កុំអីនឹងសូម្បីទីវត្តអារាមនឹងអត់មានសល់ដែរ ប្រុងដាក វិនិយោគទុនទាំងអស់ ។

កុសល : ខ្ញុំសួរបងទាក់ទងនឹងភូមិ តើបងមានទំនុកចិត្តនឹងចំពោះអ្នកជិតខាងដល់កម្រិតណាដែរ ក្នុងសម័យនេះ? ដូចអ្នកជិតខាងរបងជាមួយ ខ្មែរនិងខ្មែរ ការទុកចិត្តគ្នាជួយគ្នាទៅវិញទៅមក វាប្រែប្រួល មានការទុកចិត្តគ្នាខ្លាំង ឬតិច?

យន់ : អាចសាមគ្គីគ្នាបាន សូម្បីតែថាអ្នកចំណូល ហើយមិនថាអ្នកតស៊ូចាស់ទេ មកអត់ទេ នៅសាមគ្គីរវាងគ្នាហើយនឹងគ្នាបាន ។

កុសល : នៅទុកចិត្តគ្នាបានអត់អីទេ?

យន់ : ចា៎!

កុសល : បានដល់កម្រិតណា ច្រើន តិច មធ្យម ឬច្រើនមែនទែន?

យន់ : ១០ វាបាន៨ ។

កុសល : ដូចថាបងថាជាមួយអ្នកថ្មីដូចមិននៅតែពិបាកចឹង អ្នកចំណូល?

យន់ : ទេ! វាមាន អ្នកចំណាលដូចថា១០ ២០ វាមានមួយតែប៉ុននឹង ។ បើនិយាយរួមពិសេសរឿងកងទ័ពម៉ង ។

កុសល : ចុះបច្ចុប្បន្ននឹង ដូចថាខ្លាច ដូចថាមានម្ចាស់ការលើជីវិតលើខ្លួនឯង មានដល់កម្រិតណា?

យន់ : ទេ! សព្វថ្ងៃលោកគ្រូដូចថា រឿងដូចជាមិនទាន់រឿងទុកចិត្តខ្លួនឯងប៉ុន្មាន សូម្បីតែអ្នកជិតខាងវាមិនទុកចិត្តៗត្រង់ថា នាយទុន ដាក់មកដេញតវ៉ា ១០វាមិនសូវទាន់បានមួយដូចថាដីថ្មីជាដើម ហើយនឹងអណ្តូងដី៣ជាដើម ប្រជាជនទុកដីតែ៥០០ម៉ែត្រពីផ្លូវឲ្យគ្នា សុត្តតែនាយទុកគេដេញយកទាំងអស់ តវ៉ា ។

កុសល : បាទ! មិនសូវមានភាពម្ចាស់ការលើខ្លួនឯង ដោយសារពួកបរទេសនាយទុនច្រើន?

យន់ : ចា៎! សាមគ្គីៗ ប៉ុនថាដោះស្រាយបានយើងតែមួយ គេ៩ ហើយគេទុក៨ ។

កុសល : ចុះបងយល់ថា រដ្ឋាភិបាលបច្ចុប្បន្ននឹង អាចថាផ្តល់ភាពយុត្តិធម៌ដល់ប្រជាជនយើងកម្រិតណាដែរ តំបន់នេះ?

យន់ : ប៉ុនថាបើនៅឃុំនានាទៀត អានឹងអត់ដឹង បើចំពោះថាក្នុងឃុំដែលខ្ញុំរស់នៅសព្វថ្ងៃ បើថាមានពាក់ព័ន្ធត្រង់ណា មេភូមិអីជួយស្រុះស្រួលដែរ ប៉ុនថែមដូចថាវាមិនឈ្នះគេៗភាគវាច្រើនជាងយើង ។

កុសល : ចឹងបងទុកចិត្តថា អាជ្ញាធរមូលដ្ឋានអត់បញ្ហាទេ តែខ្លាំងៗនាយទុនខាងលើ?

យន់ : ចា៎!

កុសល : ចឹងបងពីតិចដល់ច្រើន បងឲ្យប៉ុណ្ណា វាតិច តិចបំផុត មធ្យម ច្រើនបំផុត បងយល់ថារដ្ឋាភិបាលរាល់ថ្ងៃនេះ មានភាពយុត្តិធម៌ដល់ប្រជាជនកម្រិតណា ពី១ដល់៥ចុះ ១តិចបំផុត ៥ច្រើន? បងឲ្យត្រឹមណា?

យន់ : វាភាគច្រើនវាបាន៥ ក្នុងវិនិយោគទុន បើយើងអ្នកកសិករយើងបានតែមួយទេ ព្រោះគេវាច្រើនជាងយើង មើលកន្លែងណាដែលគាបសង្កត់ ច្រើនតែបិទម៉ង ។

កុសល ៖ ចឹងអាចថាវាមិនសូវជាទុកចិត្តប៉ុន្មាន មិនសូវជាយុត្តិធម៌ប៉ុន្មានទេ រដ្ឋាភិបាល?

យន់ ៖ ចា៎! ដូចពាក្យថាសាមគ្គីដើម្បីឈ្នះហើយ ដូចកាលពួកគេវាច្រើនជាងយើងទៅមិនរួច បើយើងកសិករទៅច្រើនមែនតែយើងវាអត់មានទុនដើម្បីនឹង ហើយអត់ឈ្នះគេ ។

កុសល ៖ បើគិតរឿងគោលជំហររបស់បង ដូចថាសព្វថ្ងៃបើបងចេះតែធ្វើតាមគេប្រាប់ ដើម្បីសេចក្តីសុខផ្ទាល់ខ្លួន គ្រួសាររបស់ខ្លួន ។ ដឹងថាគេធ្វើខុសចឹងហើយ ប៉ុន្តែបងដូចថាមនហ៊ានតវ៉ាជាមួយរដ្ឋាភិបាល ឬក៏យ៉ាងម៉េច?

យន់ ៖ នែក! អារឿងត្រង់នឹងលោកគ្រូ យើងហ៊ានប្រឈមមុខមែន តែប្រឈមមុខនឹងភាគតិចដូចថាប្រជាជនភាគច្រើនគ្នាថា ឥឡូវទៅៗដូចថា១០នឹងទៅតែ៩ទេ អាប៉ុន្មានដែលគេដូចថា នាយទុន គេមិនចុះក្ស្ហាប់ដីនឹងទេ ក្នុង១០នឹងមានតែ៩ទេ វាអត់ទៅទាំង១០ទេ ហើយទៅតែ៩ វាកាត់បន្ថយវាអត់ស្មើគ្នាទៅអត់ឯកភាពគ្នា រឿងនឹងដោះស្រាយ ។

កុសល ៖ ចឹងមានន័យថាវាតិច?

យន់ ៖ ចា៎! មកចេះតែអារឿងរាយការណ៍ទៅរដ្ឋាភិបាលៗចេះតែដោះស្រាយៗមុននឹងបាន ក៏វាយូរ ។ ដូចកន្លែងដីត្រង់នេះ ម៉ាហឺ!មុនតាំងពីឆ្នាំ២០០០ប៉ុន្មាន ដូច៣-៤ឆ្នាំៗ២០០០នឹងមក ។

កុសល ៖ ចុះបងដូចថា ចំពោះការគាំទ្រចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ភូមិស្រុក បងមានចូលរួនសកម្មអីទេ?

យន់ ៖ ឯកភាព ព្រោះរដ្ឋាភិបាលដែលដឹកនាំយើងមិនចឹង ។

កុសល ៖ បាទ! ចូលរួមដែរតើ?

យន់ ៖ ហ្នឹងហើយ ។

កុសល ៖ ចំពោះបងឲ្យផ្ទាល់ៗចូលរួម?

យន់ ៖ ចូលរួមកសាងមកពីនេះ ដូចថាជាសាលាដូចជាផ្លូវដូចជាអីអានឹងឯកភាព រដ្ឋាភិបាលយើងជួយដឹកនាំយើងឲ្យរីកចំរើន ហើយឲ្យជឿនលឿន ។

កុសល ៖ ហើយបងខ្លួនឯងបានចូលរួមក្នុងប្រជុំក្នុងអីនេះទេ?

យន់ ៖ ចូលរួមជាហូរជាហែរដែរ ។ ចុះសព្វថ្ងៃរដ្ឋាភិបាលអត់មានទំនាស់ៗតែរឿងវិនិយោគទុន ។

កុសល ៖ បងសុំលើកឧទាហរណ៍ សកម្មភាពអីខ្លះដែលបងអាចជួយចូលរួមអ្នកភមិអ្នកស្រុកយើងដែលបងបានចូលរួមជួយ?

យន់ ៖ ដែលបានចូលរួមជួយក្នុងឃុំយើង មានតែជួយជំរុញឲ្យរីកចំរើនតទៅមុខទៀត ។

កុសល ៖ ដូចឧទាហរណ៍ៗបងធ្វើអីខ្លះ?

យន់ : ឧទាហរណ៍ជួយរីកចំរើន យើងបង្កើតផល ជួយរុញច្រានដូចគេថាក្នុងជួរកង់ទ័ព ហើយនឹងប្រជាជននឹងពង្រឹងឲ្យរដ្ឋាភិបាលយើងនឹង មានការដឹកនា មានទឹកចិត្តនឹងដឹកនាំតទៅមុខទៀត ។

កុសល : ចឹងបងគិតថាខ្លួនឯងបានចូលរួមដែលនៅក្នុងបញ្ហានឹង?

យន់ : ចា៎!

កុសល : ច្រើន ឬតិច ពី១ដល់៥?

យន់ : អានឹងចឹង ។

កុសល : ច្រើន តិច និយាយឲ្យត្រង់ខ្លួនចូលបានច្រើន ឬតិច?

យន់ : រឿងខ្ញុំក្នុងអារម្មណ៍ខ្ញុំសព្វថ្ងៃ រដ្ឋាភិបាលជួយនឹង គឺថា១០ភាគរយវាទៅ៨ នៅ២ភាគរយ ដូចថានៅវិនិយោគទុនដែលគាបសង្កត់យើងត្រង់ដីនឹង ។

កុសល : អត់ទេ សំនួរនេះចង់ថា ខ្ញុំសួរថាតើបងផ្ទាល់បានចូលរួមដូចថាសកម្ម ជួយភូមិស្រុក អត់បាច់និយាយពីរដ្ឋាភិបាល?

យន់ : ក្នុងភូមិយើង?

កុសល : បាទ! ក្នុងភូមិយើង បងចូលជួយអ្នកជិតខាង ដាំស្រូវ ដាំពោត មានសកម្មភាពជួយចឹងទេ មានទេ?

យន់ : ជួយ អានឹង១០ ជួយទាំង១០ អានឹងព្រោះសាមគ្គី យើងជិតខាងអ្នកស្រុកភូមិតែមួយ ព្រោះយើងរាប់រកគ្នា សញ្ជាតិខ្មែរដូចតែគ្នា យើងជួយសហការ ។

កុសល : ហេតុអីបានចឹង ដោយសារពីមុនមក ឬទើបឥឡូវនឹងទេ?

យន់ : ទេ! និយាយរួមតាំងពីម៉ែឪមក បើយើងរស់នៅជាមួយអ្នកស្រុកសញ្ជាតិខ្មែរយេង ហើយនៅជុំវិញអ្នកជិតខាងនឹង យើងជួយគ្នាខុសក្ដី ត្រូវក្ដី យើងជួយជុំរុញគ្នាទៅវិញទៅមក ។

កុសល : ព្រោះបងមួយគាត់ប្រាប់ថា តាំងពីជំនាន់៧៩ ៨០មក ដូចថាប៉ុល ពត តាម៉ុកអីគាត់នៅនឹងគាត់បង្រៀនឲ្យរបៀបដាំដុះ ដូចថាជួយគ្នាទៅវិញទៅមក ដូចបងថាពីមុនចឹង បងគិតថាអានឹងជាទំនៀមទម្លាប់ពីមនមកដែលបន្តមករហូតដល់ឥឡូវ ឬថ្មីៗនេះទេ?

យន់ : ចា៎! អានឹងចឹងដែរ កាលពីជំនាន់តាម៉ុកតែរៀនសូត្រយើងរៀនតាំងពី មាន់ ទា ជ្រូក ផ្កែ ផ្ការអីទាំងអស់ បើថាដូចថាយើងធ្វើអីយើងចែកគ្នាហូប យើងសាមគ្គីគ្នាដើម្បីឈ្នះ អានឹងដូចគ្នាចឹង ។

កុសល : ចឹងការទុកចិត្តលើអាជ្ញាធរភូមិស្រុក គឺថាមានដលកម្រិតណាដែរ តិច ច្រើន?

យន់ ៈ ចា៎! រឿងភូមិស្រុកសព្វថ្ងៃ១០ ទាំង១០ ព្រោះអីម៉ែឪយើងអ្នកដឹកនាំឲ្យយើងសាមគ្គីគ្នា ឲ្យយើងដើម្បីល្អ ដើម្បីឈ្នះ ។

កុសល ៈ ចឹងខ្ញុំសួរទៀតថា តើរដ្ឋាភិបាលបច្ចុប្បន្ននឹង បានផ្តល់សន្តិសុខ ដល់បង និងក្រុមគ្រួសារបងដល់កម្រិតណា ពី១ដល់៥? ១តិច ៥ច្រើន ។

យន់ ៈ សព្វថ្ងៃវាអភិវឌ្ឍន៍ ត្រង់នឹងវា ។

កុសល ៈ ផ្តល់នៅសន្តិសុខ ការពារសន្តិសុខដល់គ្រួសារយើង ដល់ភូមិនេះមានអារម្មណ៍កក់ក្តៅដល់កម្រិតណា?

យន់ ៈ សព្វថ្ងៃ ភាគរយ បានថាចុះ ។

កុសល ៈ និយាយឲ្យត្រង់មានអី ។ ចង់ដឹងថាតើរដ្ឋាភិបាលជួយផ្តល់សន្តិសុខគ្រប់គ្រាន់ដែរទេក្នុងស្រុកភូមិនេះ ដល់កម្រិតណាដែរមាន?

យន់ ៈ សព្វថ្ងៃតាមដែលក្តាប់មើល ដែលមេភូមិចេះតែជួយ ចេះតែស្មើរដូចថាក្នុងភូមិចឹង មើលក្នុងចំណោមក្នុងភូមិយើង ឬឃុំយើង ដូចជឿនលឿន ដូចជាសាលាដូចជាអីរដ្ឋាភិបាលពីលើមកឧបត្ថម្ភសីងនឹងថាគ្រប់គ្រាន់ភាគរយ ។

កុសល ៈ ចឹងរដ្ឋាភិបាលបច្ចុប្បន្នការពារប្រទេស បងគិតថាការពារប្រទេសជាតិយើង បូរណភាពដែនដីយើងបានកម្រិតណាដែរ ជម្លោះជាមួយថៃក្តី?

យន់ ៈ សព្វថ្ងៃវាបានភាគរយៗមកយើង ដូចប៉ុន្មានឆ្នាំមុន វាចេះរកាំរកូស សព្វថ្ងៃវាបានភាគរយមកយើងវិញរឿងតស៊ូតាមព្រំដែន ។

កុសល ៈ ហើយបងមានជំនឿលើយុត្តិធម៌ ប្រព័ន្ធយុត្តិធម៌ដល់កម្រិតណាដែរ?

យន់ ៈ អានឹងជឿជាក់នៅលើរដ្ឋាភិបាលដោះស្រាយព្រំប្រទល់កម្ពុជាយើង បានភាគរយ ។ ម៉េចបានភាគរយ យើងត្រូវសាមគ្គីគ្នា ផ្លូវដឹកស្បៀងចេញចូល ជាប្រជាជននិងប្រជាជនយើងត្រូវគ្នាអស់ហើយ ចេញចូលបាន ។ ប៉ុន្មានឆ្នាំមុនដូចអត់មានទេ គួរមុខយក្សដាក់គ្នា ។

កុសល ៈ ខ្ញុំសួរត្រឡប់មកមុននឹង ដូចថាបច្ចុប្បន្ននឹង ដូចបងគាំទ្រឲ្យរដ្ឋាភិបាលនឹងកាត់បន្ថយឥទ្ធិពលជនបរទេសនឹង គគាំទ្រខ្លាំង?

យន់ ៈ ចា៎! ខ្លាំងហើយភាគរយពីកសិករ រស់លើដី ។

កុសល ៈ ត្រឡប់ទៅពីមុនវិញ សួរក្នុងអំឡុងពាឆ្នាំ៨ខែ២០ថ្ងៃ គឺថា បងឯងមើលអក្សរដាច់ដែរតើ?

យន់ ៈ អត់ទេ ។

កុសល ៈ មែន? តែអត់បំពេញខ្លួនឯងម៉ង ស្រួល លឿន?

យន់ : អត់ទេ ។

កុសល : ខ្ញុំអានហើយ សំនួរសួរថា ខ្ញុំធ្វើតាមបញ្ជារបស់មេដឹកនាំជំនាន់នោះ ពីព្រោះតែខ្ញុំជឿលើមាគ៌ាបដិវត្តន៍របស់អង្គការ ថាជាមាគ៌ាមួយដ៏ត្រឹមត្រូវ? តើបងជឿទៅលើរបបពាផ្នាំ ៨ខែ ជឿជាក់ទៅលើមាគ៌ាថា មាគ៌ាបដិវត្តនោះវាល្អត្រឹមត្រូវដែរទេ ពី១ដល់៥ ។ ១តិចបំផុត មិនជឿ?

យន់ : ម៉ាជំនាន់នោះភាគច្រើនមិនជឿ ត្រង់សម្លាប់មនុស្សចោលអស់ ។

កុសល : បងមិនជឿទេ?

យន់ : ចា៎!

កុសល : ភាគតិច?

យន់ : ចា៎! ភាគតិច បើអស់បងអស់ប្អូន អស់ម៉ែអស់ឪ ។

កុសល : អត់ជឿថាល្អ?

យន់ : ចា៎! មិនជឿ ។ បានជាថាមិនជឿក្នុងមួយពោះៗអស់រលីង នៅសល់អាខ្លះនៅសល់២ អាខ្លះសូន្យ ។

កុសល : បងជឿគោលនយោបាយរបស់ប៉ុល ពត ជំនាន់នឹង គាត់ធ្វើឲ្យប្រទេសជាតិរីងមាខ្លាំងក្លាដែរទេ?

យន់ : អត់មានទេ បានជាថាចុះចំការកៅស៊ូ ចំការអីយើងដឹកទៅចិនអស់រលីងមួយជំនាន់នោះតាម ដែលក្តាប់មើលទៅធ្វើស្រូវអង្ករបានរាប់រយរាប់សែន ។ ហើយមិនដែលមានសល់នៅតែ ហូបបបរលាយដំឡូង ហូបគល់ល្ហុង គល់អី បានមិនជឿជាក់ ។

កុសល : ដូចថារាល់ថ្ងៃនេះ បងតែក្នុងចិត្ត នៅចេះនឹកឃើញព្រឹត្តិការណ៍ដល់របបខ្មែរក្រហមដែរអត់?

យន់ : សព្វថ្ងៃ ។

កុសល : ដែលយើងនឹកឃើញសកម្មភាពគួរឲ្យភ័យខ្លាចជំនាន់នឹងដែរអត់?

យន់ : ដូចវាថា ខ្លាចដូចវាព្រោះអីសភាពការណ៍ត្រង់នឹង បើដូចសព្វថ្ងៃ ព្រំដែនវាជម្លោះចឹង ទៅមុខទៀតដឹងរបៀបម៉េច ។

កុសល : ដែលសុបិន្តអាក្រក់ យល់សប្តិអាក្រក់?

យន់ : អត់ដែរ ។

កុសល : ចុះទំនាក់ទំនងជាមួយអ្នកដទៃ អ្នកជិតខាងអី នៅមានពួកម៉ាក មិត្តភ័ក្តច្រើនទេ?

យន់ ៖ អត់អីទេ ខ្ញុំនិយាយរួមនៅកន្លែងណាក៏ដូចជាកន្លែងណា អត់មានបង្កបញ្ហាអីទេ អត់ទេ លែងមាន ។

កុសល ៖ ចេះតែមានអារម្មណ៍ឆាប់ភ្ញាក់ផ្អើល ឬក៏ឆាប់ភ័យខ្លាចអីទេ?

យន់ ៖ អត់ ធម្មតា សព្វថ្ងៃ បើសិនជានៅក្មេងដូចពីមុនវិញ តាំងពីមានសង្គ្រាមតាមជាយដែន សឹងថាចូលតស៊ូប្រឆ្លុកនឹងគេ ប៉ុន្តែទាល់តែចាស់ហើយ ព្រោះខឹងណាស់ដែលគេលេប ត្រវាក់ទឹកដីកម្ពុជាយើងអស់ សព្វថ្ងៃគ្រប់ច្រក មើលឃើញស្រាប់ហើយ ពីមុនដីយើងធំ ។

កុសល ៖ បើសិនជារដ្ឋាភិបាលអំពាវនាវឲ្យធ្វើទ័ព ប្រហែលជាបងបញ្ជូនកូន បញ្ជូនចៅទៅ?

យន់ ៖ អត់មានកូនទេសព្វថ្ងៃ មានអាមួយអាយុ១០ឆ្នាំនៅវត្ត អាមួយ២៥ ២៦នេះកូន២នេះ ៦ង ។

កុសល ៖ ចុះបងមានពិបាកផ្តោតអារម្មណ៍ទៅលើធ្វើអ្វីមួយ ដូចថាបញ្ហាសតិអារម្មណ៍ មានប៉ះពាល់ អត់ជំនាន់នោះ?

យន់ ៖ សតិអារម្មណ៍កាលជំនាន់នោះ ភ័យព្រួយតែគេវ៉ៃចោល ដល់មកបច្ចុប្បន្នខ្លាចតែគេគាប សង្កតយកទឹកដីកម្ពុជាអស់ ។

កុសល ៖ ចឹងអត់មានពិបាកផ្តង់អារម្មណ៍ធ្វើអ្វីមួយ បញ្ហាធម្មតាៗ?

យន់ ៖ ចា៎! ធម្មតាៗ សព្វថ្ងៃនឹកឃើញ ។

កុសល ៖ ចុះទទួលទានដំណេកអីម៉េចដែរបង ស្រួលទេ ដេកលក់ អត់មាន?

យន់ ៖ ចា៎! សព្វថ្ងៃធម្មតាភ័យព្រួយខ្លាចតែគេយកដីហើយខ្ញុំក្រប៉ុននឹង សព្វថ្ងៃធ្វើកូនខ្ទមតូចមួយ ប៉ុននោះនៅ២នាក់ម៉ែកូន ។

កុសល ៖ ដែលមានអារម្មណ៍ប្រុងខ្លួនជានិច្ច ចេះប្រយ័ត្នៗខ្លួន?

យន់ ៖ ទេ! ការប្រុងប្រយ័ត្នៗទូងទាំងទៅបើថាសៀមវាមិនព្រមចរចា ក្រែងលវាចូលមកក៏យើង អស់ទឹកដី ។

កុសល ៖ មានអារម្មណ៍ឆាប់ខឹង ឆាប់អីទេ?

យន់ ៖ អារម្មណ៍ដូចព្វទូងទាំង ញាក់សាច់ឆាប់ខឹង ។

កុសល ៖ ដូចនៅទទេរឆាប់ខ្ទង?

យន់ ៖ អត់ ។

កុសល ៖ ឧបមាថាទទេរៗឆាប់ខឹង?

យន់ ៖ អត់ៗមាន ព្រោះអត់មានទំនាស់អីចិត្តខឹង ទំនាស់ពេលដែលទូងទាំងម្តងៗនឹកតូចចិត្តថាគេ មកលេបត្របាក់ទឹកដីកម្ពុជាយើងរួមតិចម្តងៗ វាចង់អស់ ។

កុសល ៖ បងតែមានអារម្មណ៍ថាចៀសវាងសកម្មភាពទាំងឡាយណា ដែលបណ្តាលឲ្យនឹកឃើញដល់ព្រឹត្តិការណ៍ក្នុងសម័យនោះ សម័យ៣ឆ្នាំ៨ខែ ដូចថាអត់ចង់គិតទៀត ។

យន់ ៖ អត់ បំភ្លេចចោល ។

កុសល ៖ មានដែលប្រឹង ព្យាយាមគិតទេ?

យន់ ៖ អត់មានគិតទេ សព្វថ្ងៃគិតឃើញថា ដីព្រំប្រទល់កម្ពុជាយើង ដែលសៀមវាកាត់ឮាតនឹងនឹកឃើញថាអារម្មណ៍តែប៉ុននឹងខ្វាចលវតែ ។

កុសល ៖ ប៉ុនគេថាសម្លាប់ឪពុកបង?

យន់ ៖ ចាំ!

កុសល ៖ ចឹងបងដែលគិតឃើញឪពុកបងស្លាប់របៀបម៉េច គេសម្លាប់របៀបម៉េច អត់ដែលឃើញ?

យន់ ៖ ទេ! គិតឃើញ លោកគ្រូ ប៉ុនកាលកន្លងហួសទៅហើយមិនដឹងរបៀបម៉េច យើងជាស្រីចឹង ការឈឺចាប់នៅតែឈឺចាប់ លោកពុកមួយទាំងមូលគេសម្លាប់ចោលមិនដឹងមូលហេតុអីអត់តែប៉ុននឹង ។

កុសល ៖ បងនៅចាំបានព្រឹត្តិការណ៍នៅសម័យនោះ?

យន់ ៖ វានៅស្ទើរ វាអត់ដឹងហេតុផលពីដើមមក ប៉ុនដឹងថាសម្លាប់ៗតែមិនដឹងថាសម្លាប់មូលហេតុអី ។

កុសល ៖ នៅចាំៗ ពេលគេចាប់យកទៅ អត់ចាំ?

យន់ ៖ ចាំ! ប៉ាខ្ញុំគាត់ចាប់បានគេចាប់នៅបន្ទាយនេះ ដល់យកទៅៗគេយកទាំងខ្សែៗកូនទាហានទាំងប៉ុន្មានៗ កាលដែលខ្ញុំទៅជួបនឹង លានដ្ឋានគេដាក់ធំ ដល់ពេលនេះគេរំដោះគេរើសកាប៉ាសែបៗ ដោយៗសែប អាស្តង់សែប គេរើសតាមរយៈនឹងៗ មួយជំនាន់នឹងគេថាចឹង ដល់ពេលយើង៣ឆ្នាំគេថាកងតូច កងធំៗ ដល់យើងមកសព្វថ្ងៃនេះ មិនដឹងថាគេប្រើថាម៉េចទៀត ។

កុសល ៖ ចុះជំនាន់នឹង បងចាត់ទុកខ្លួនឯងជាជនរងគ្រោះ ឬក៏ជាអ្នកធ្វើការឲ្យរបបនោះ ឬក៏ថាមិនមែនទេ?

យន់ ៖ អត់ទេ ។

កុសល ៖ ជនរងគ្រោះ?

យន់ ៖ ជនរងគ្រោះ ព្រោះអីនៅស្ទើរទាំងអស់ ព្រោះអីអាយុប៉ុននឹង ម្តាយម៉េម៉ាយកំព្រាដែលឪយកទៅវៃចោល នៅចិញ្ចឹមប្អូន ។

កុសល : បាទ! នៅក្នុងកងរបស់ពួកបងៗធ្វើការជាៗអីគេនៅក្នុងកងចល័តចិន?

យន់ : ចា៎! កងចល័ត យើងលី សែង កាប់គាស់ទប់ទំនប់ ជីកប្រឡាយ ។

កុសល : ចុះមេកងចល័តនីឈ្មោះអី មានចាំ?

យន់ : មួយជំនាន់នោះ មើលគេយកទៅវ៉ៃចោលអស់ហើយ ។

កុសល : ចិន?

យន់ : ចា៎! គ្រូ អៀត, បង នី, អូ!នៅគ្រូ ណាង មួយសព្វថ្ងៃនៅបុសខ្នុរនៅគ្រូណាង ប៉ុនចាស់ជរាហើយ ។

កុសល : បងដែលឃើញមានដូចថាពួកនឹងមានការកាប់សម្លាប់ទេនៅកន្លែងនឹង?

យន់ : អត់មាន ព្រោះតែមើលកាលពីបងអៀត នៅនឹងគេថាបងអៀតនឹងខ្សែខ្មាំងដូចថាដឹកនាំគេយកគាត់ទៅវ៉ៃចោល ។ ហើយដូចពី៧៧មក បងអៀត នឹងគេថាបេះចុះគេយកទៅវ៉ៃចោល ។ ដល់មកក្រោយទៀត គ្រូនី នឹងក៏គេយកទៅវ៉ៃចោលដែល គេថាយើងខ្សែ ។

កុសល : ពួកមេកងនឹង មានដែលបញ្ហា ដូចថាបញ្ហាបងធ្វើអីធ្ងន់ធ្ងរដែរទេ?

យន់ : អត់មានទេ លោកគ្រូ មួយជំនាន់ដែលកងចល័តពួកខ្ញុំនៅនឹង ដូចថាខែចំការគេឡើងឲ្យមកធ្វើចំការ ដល់ខែប្រូតកាត់ឡើងមកប្រូតកាត់ឡើងមកប្រូតកាត់ ។ តែស្ទូងអត់បានស្ទូងទេ ដល់ខែទៅជីកទំនប់ទប់ប្រឡាយទៅ បានឡើងទៅខាងចិន ។

កុសល : ហើយបងមានដឹងថា ពួកនឹងធ្វើប្រព្រឹត្តខុសទេ ជំនាន់នឹង ដឹងតែធ្វើ?

យន់ : ទេ! ដឹងតែរឿងមេកងអីខ្ញុំនឹង អត់មានដែលឃើញធ្វើ ឃើញតែគេយកគាត់ទៅវ៉ៃចោលថា ។

កុសល : គេយកគាត់នឹងទៅវ៉ៃចោល យកមេកងទៅវ៉ៃចោល?

យន់ : ចា៎!

កុសល : មានដឹងហេតុផលទេ?

យន់ : អត់ដឹងហេតុផលទេ ។

កុសល : ហើយបងភ័យខ្លាចទេ?

យន់ : ភ័យដែរ ដឹងធ្វើម៉េចបើមេទៅហើយ នៅតែកូនៗ ដល់កូនគេបេះតែបែងចែកចូលទៅនេះចូលទៅនោះមិនដឹងជាម៉េច ប៉ុនក្នុងកូនៗនឹងវាមានដែល មានដូចថាខ្ញុំនឹងខ្សែគ្រូឯងចិន ថាឥឡូវជំនាញបេះៗ ធ្វើបេះៗ ដល់យកមេទៅហើយ កូនទៅតាម ។ ខ្ញុំបិសៗនឹងគេដែរ ប៉ុនគ្រាន់ថាបេះមេគេចូលថ្មីមក គេថាអ!ទៅណាមនុស្សស្លូត គ្នាមិនដឹងអី បានជារស់មួយគ្រា ។ កុំអីខ្ញុំទៅមួយខ្សែជាមួយមេនឹងគេដែរ គេថាឯងខ្មាំងខ្មែរសអីគេណាណេ ។

កុសល ៖ ដូចថាឥឡូវភាគច្រើនទៅយើងមើលមកស្រុកយើងហាក់ដូចជាយើងមានអ្នកជនរងគ្រោះផង ពួកអតីតអី របបនឹងវាបែងចែកគ្នា ខុសពីអ្នកថ្មីនិងអ្នកចាស់ដូចបងប្រាប់ចឹង ។ ឥឡូវដល់ដំណាក់កាលមួយពេលធ្វើសមាហរណកម្ម គេដាក់បញ្ចូលពួកអតីតចូលរដ្ឋាភបាលសព្វថ្ងៃ ចឹងយើងក្លាយជាប្រជាជនតែមួយទៅហើយ យើងលែងគិតពីមុនទៅពីក្រោយ យើងចង់បានសន្តិភាព ចង់បានអភិវឌ្ឍន៍ ។ ប៉ុន្តែនៅតែមានបញ្ហាមួយថា តើយើងធ្វើម៉េចឲ្យមានការផ្សះផ្សា ពីព្រោះអ្នកជនរងគ្រោះរបបនឹង ដូចបងផ្ទាល់បាត់ឪពុកម្តាយ បេះតែឆ្ងល់ហេតុម៉េចបានគេសម្លាប់ចោលទទេរ ៗ ចឹង?

យន់ ៖ ចា៎!

កុសល ៖ ហើយចម្លើយនេះ គ្មានអ្នកណាឆ្លើយបានទេ ។ ហើយឥឡូវនេះ គឺដូចសព្វថ្ងៃនេះ គឺមានតុលាការមួយនៅភ្នំពេញ មានអន្តរជាតិផង មាន ខាងខ្មែរផង តើបងមានតាមដាន?

យន់ ៖ អត់ដែលបានតាមដាន ថាសព្វថ្ងៃនឹងថាគ្មាន ។

កុសល ៖ ចុះដែរដឹងឮមាន?

យន់ ៖ អត់ដែលដឹងឮទេ ។

កុសល ៖ អត់ដែលដឹងឮ បើសព្វថ្ងៃនេះមានតុលាការមួយនៅភ្នំពេញ មានអន្តរជាតិផង មានខាងខ្មែរផង តើបងមានតាមដាន?

យន់ ៖ អត់ដែលបានតាមដាន សព្វថ្ងៃគ្មាន ។

កុសល ៖ ដែលដឹងឮមាន?

យន់ ៖ អត់ដែលដឹងឮទេ ។

កុសល ៖ អត់ដែលដឹងទេ?

យន់ ៖ ចុះបើអត់ដែលមានវ៉ាដ្យូសព្វថ្ងៃ ដែលគ្មានស្អីសុទ្ធសាធ សូម្បីតែស្អីក៏គ្មាន ។

កុសល ៖ អត់ដែលឮសោះពីតុលាការ?

យន់ ៖ ចា៎! បើអត់មានវ៉ាដ្យូស្តាប់ អត់ដែលមានវ៉ាដ្យូណាអត់មាន អត់ដឹង ។

កុសល ៖ តា ដន គាត់ទៅដែរ?

អ្នកជិតខាង៖ តា ដន ទៅតុលាការ យកមេៗទៅកាត់ទោស ។

កុសល ៖ តា ដន នឹងគេឲ្យទៅ?

អ្នកជិតខាង៖ចា៎!

កុសល ៖ ហេតុអីគាត់បានទៅ?

អ្នកជិតខាង៖មិនដឹងយ៉ាងម៉េចខ្ញុំមិនដឹងដែរ ។

កុសល ៖ តា ដន គេឲ្យគាត់ទៅមើលកាត់ទោសម៉េចអីម៉េច?

អ្នកជិតខាង៖ហ្នឹង កន្លែងនាំទៅដើរកម្សាន្តដើរអី ។

កុសល ៖ ចឹងបើគិតដល់ឪពុករបស់បង ធ្វើម៉េច ដើម្បីឲ្យមានការផ្សះផ្សារបស់អតីតកាលរបស់ខ្លួន ទី១ ខ្ញុំចង់ឲ្យឃើញមេដឹកនាំប៉ុល ពត ទទួលទោសកម្រិតធ្ងន់ តើបងឯកភាពដល់កម្រិតណា ពី១ដល់៥ ។ ១ថាតិច ៥ថាច្រើន?

យន់ ៖ ព្រោះឪពុកកំហឹងឈឺចាប់ វាមាន៥លោកគ្រូ បើបាត់បង់ឪពុកស្លាយ ប៉ុន ។

កុសល ៖ ចឹងចង់ឲ្យគេយកទៅកាត់ទោស?

យន់ ៖ ចា៎!

កុសល ៖ នៅរាល់ថ្ងៃនឹង មានខៀវ សំផន, មាននួន ជា ។ ចឹងបងចង់ឲ្យដាក់ទោសទៅលើមេដឹកនាំនឹង?

យន់ ៖ ចា៎! ហ្នឹងមិនដឹងជាថារម៉េចក៏ដោយ បើទូទៅមួយកម្ពុជា ការឈឺចាប់ដែលខឹងៗ ។

អ្នកជិតខាង៖បើសិនជាខ្ញុំវិញ បងក៏បាត់ ឪពុកនៅ ប៉ុនបាត់បង២ និងបងជីដូនមួយ គឺថាបាត់អស់ច្រើន បើត្រង់ខ្ញុំបើថាមកសម័យនេះទៅហើយ មិនបាច់ទៅគិតកាត់ទោស កាត់អីទេ គិតតែពីរៀងកសាងប្រទេសជាតិឲ្យតែរីកចំរើនទៅ អ្នកបាត់ៗទៅហើយ ។

កុសល ៖ ចឹងមានន័យថា មិនបាច់ចាំដាក់ទោសគាត់ទេ?

អ្នកជិតខាង៖ មិនបាច់ចាំដាក់ទោស បើរឿងកន្លងហួសទៅហើយ ។

កុសល ៖ ចុះបងវិញ បងយល់យ៉ាងម៉េច ព្រោះគាត់មាន?

យន់ ៖ ខ្ញុំវា ម៉ែអូននេះថា ការកន្លងហួសទៅហើយ ។

អ្នកជិតខាង៖ យើងថាខ្មោចងាប់កប់បាត់ស្អុយហើយ យើងទៅគស់ឡើងទៅធ្វើអីទៀត ។

យន់ ៖ ចា៎! មិនដឹងជាគាស់ៗមានតែឈឺចាប់ នៅតែឈឺចាប់ចឹង ។

កុសល ៖ ចឹងបងដូចថាមិនសូវជាចង់ឲ្យឃើញមានថ្នាក់ដឹកនាំយកមកផ្តន្ទាទោសទេ អត់ចង់?

យន់ ៖ អានហ្នឹងធ្វើទៅក៏វា ខ្លាចអាបត់នឹងដែរ ។

កុសល ៖ ចឹងបងចង់ឲ្យសង្គមបច្ចុប្បន្ន បំភ្លេចទៅពីអតីតកាល?

យន់ ៖ ចា៎! ចង់ឲ្យវាសាបរលាបពីប៉ុននឹងតទៅកុំឲ្យវា ។

កុសល ៖ ចុះបងជឿលើកម្មផលចឹង?

យន់ ៖ ចា៎! និយាយជឿកម្មផល ភាគរយម៉ង ។

កុសល ៖ ជឿខ្លាំងភាគរយ?

យន់ ៖ ចា៎!អានឹងមកពីកម្មយើងផលយើងវាមិនដល់នឹង បានវាទៅកម្រិតនឹងដូចពាគេថាមកពីយើងអត់សំពាយបានយើងមិនមាននឹងគេនៅតែក្រ ខំយ៉ាងណាក៏មិនមានបានៗមួយគ្រប់ៗ ។

អ្នកជិតខាង៖ អារឿងកាប់សម្លាប់ជំនាន់នោះ មិនថាក្រុមគ្រួសារៗណាទេ សុទ្ធតែក្រុមគ្រួសារឲ្យតែក្នុងប្រទេសខ្មែរ ។

យន់ ៖ និយាយរួមមួយប្រទេស ឲ្យតែប្រទេសកម្ពុជា គឺទូទៅហើយ តិចច្រើនតូចធំ ។

កុសល ៖ ចឹងបើបងមិនបានដឹងពីតុលាការនឹង ពិបាកសួរដែរ ឧបមាថាបើសិនជាបងដឹងថាមានតុលាការកាត់ទោសនឹង តើវានាំឲ្យមានការផ្សះផ្សាជាតិដែរទេ? តិច ឬក៏ច្រើន?

យន់ ៖ នៅតែមានតិចហើយច្រើន តូចហើយធំ ការនោះ បើសិនជាដូចឧទាហរណ៍ថាខ្ញុំមួយចឹងថាខឹង អាការកាប់សម្លាប់ បងប្អូន ពូជពង្សវាតាំងអស់នឹង នៅតែខឹង នៅតែបេះតែកើតឡើងៗហើយ ។

កុសល ៖ ចឹងត្រូវបំភ្លេចចោលទៅ?

យន់ ៖ ចា៎! ទាល់តែយើងនឹកពេក ។

កុសល ៖ ប៉ុន្តែបើខ្ញុំសួរខុសគ្នា តើតុលាការនឹងអាចធ្វើការផ្សះផ្សា ឬក៏ធ្វើឲ្យមានច្របូកច្របល់តុលាការ?

យន់ ៖ ការផ្សះផ្សាតាមសម្រួល ។

អ្នកជិតខាង៖មានការផ្សះផ្សា ប៉ុន្តែប្រជាពលរដ្ឋភ័យខ្លាច ។

កុសល ៖ ហេតុអីបានប្រជាពលរដ្ឋភ័យខ្លាច?

អ្នកជិតខាង៖ភ័យខ្លាចចុះដូចថាកាត់ទោសពូ-កចឹង ចុះនៅកូនចៅពូ-កមិននៅបែកសាខា ។ កាត់ទោសបានតែម្នាក់ទេ ចុះឧទាហរណ៍ថាពូ-កនឹងមាន បុត្រប្រុស៥ ហើយបុត្រស្រី២ ៧ ។

កុសល ៖ កូនចៅគាត់ភ័យ?

អ្នកជិតខាង៖ហើយកាត់ទោសបានតែមួយទេ ចឹងខ្ញុំខ្លាចត្រង់នឹង បើថាល្មមៗកាយកប់លុបចោលទៅខ្មោចងាប់កប់ៗឲ្យជិតកុំឲ្យគាស់ឡើងធ្វើអី តាមគំនិតគិតឲ្យឃើញ បើថាលោកគ្រូថាខុសក៏ខុសទៅ ។

កុសល ៖ អត់ទេ គឺចង់ដឹងពីមតិរបស់បង ខ្ញុំអត់អាចខុស ។

កុសល ៖ ចឹងបងមានដែលចាប់អារម្មណ៍ចង់តាមដានតុលាការដែរទេ តិចតួច?

យន់ ៖ អត់ទេ! លោកគ្រូគិតថា ដូចថាខ្មោចងាប់ទៅមិនដឹងរើមកវិញ នៅតែនេះ បើវាមិនដឹងហេតុផល សព្វថ្ងៃវាមិនដែលបានស្តាប់ គ្មានវ៉ាដ្យូ វាហីៗទៅឪពុកស្លាប់ទៅហើយក៏វាមិនបានគិតឃើញថា អាដ័យក៏ស្លាប់គ្រោតក៏ស្លាប់ដចតែគ្នាវាទូទៅហើយមួយកម្ពុជាយើង បើ

ថាលើករឿងនឹងឡើងទៀត បេះតែនៅកំហឹងទល់នឹងកំហឹង ។ ដល់ហើយកូនចៅជំនាន់ក្រោមបេះតែខំ ។

កុសល ៖ ចុះបងដែលស្គាល់ឌុច?

យន់ ៖ អត់ស្គាល់ ។

កុសល ៖ គេកាត់ទោស?

យន់ ៖ អត់ស្គាល់ ។

កុសល ៖ ចំពោះអត្ថន័យនៃប្រជាពលរដ្ឋល្អម្នាក់ តាមនិយមន័យរបស់បងៗយល់ថា អ្វីទៅជាប្រជាជនល្អម្នាក់? ប្រជាជនល្អម្នាក់ គឺជាមនុស្សដែលហ៊ានពលីជីវិតដើម្បីការពារអធិបតេយ្យភាពជាតិ និងអត្តសញ្ញាណរបស់ជាតិ ។ បងឯកភាពទេ?

យន់ ៖ អាត្រង់នឹងឯកភាព ព្រោះយើងទាល់តែមាន២នឹងបានយើងពង្រឹងប្រទេសជាតិបាន ។

កុសល ៖ ប្រជាជនកម្ពុជាល្អមួយរូប គឺជាមនុស្សត្រៀមខ្លួនស្រេច ដើម្បីអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល? ឯកភាព តិច ឬច្រើន?

យន់ ៖ អានឹង១០០ភាគរយ ទាល់តែមានរដ្ឋាភិបាល បានមានដួរកងទ័ព ពង្រឹងកម្ពុជាយើង ។

កុសល ៖ ប្រសិនបើប្រទេសថៃឈ្លានពានដណ្តើមយកប្រាសាទព្រះវិហារ តើបងធ្វើយ៉ាងណា? ១ខ្ញុំនឹងធ្វើអ្វីៗទាំងអស់ ដែលរដ្ឋាភិបាលដាក់បញ្ជាឲ្យអនុវត្ត?

យន់ ៖ ត្រូវតែធ្វើតាមទប់ស្កាត់ ។

កុសល ៖ ទាំងស្រុង?

យន់ ៖ ចា៎! កុំឲ្យគេយកបានព្រោះគេរ៍ គេរតំណែលតាំងពីដូនតាមក ។

កុសល ៖ ក្នុងនាមជាជនស្នេហាជាតិខ្ញុំនឹង ប្រយុទ្ធប្រឆាំងដើម្បីការពារប្រាសាទនេះ?

យន់ ៖ ចា៎! ដើម្បីតស៊ូយកជ័យជំនះ ។

កុសល ៖ បាទ! តិច ឬក៏ច្រើន?

យន់ ៖ ភាគរយ ។

កុសល ៖ ខ្ញុំនឹងតវ៉ា ប្រសិនបើរដ្ឋាភិបាលមិនអាចការពារប្រាសាទនេះបាន?

យន់ ៖ ដើម្បី ។

កុសល ៖ ប្រសិនជារដ្ឋាភិបាលមិនអាចការពារប្រាសាទបានទេ បងហ៊ានតវ៉ា?

យន់ ៖ ហ្នឹងទាល់តែតវ៉ា ព្រោះគេរ៉ួតំណែលពីដូនតាយើងមកឲ្យគេយករបៀបម៉េចបាន បើយើងខំតាំងពីដើមមកទាល់តស៊ូអស់រាប់ពាន់រាប់រយនាក់ ហើយឲ្យទៅគេរបៀបម៉េច ព្រោះគេរ៉ួដូនតា ។

កុសល ៖ កត្តាទាក់ទងនឹងរឿងតុលាការ ការកាត់ទោសមេដឹកនាំជំនាន់(៣ឆ្នាំ)៨ខែ ពីដូចថា តើបងពេញចិត្តឲ្យតុលាការនឹងរៀបចំឡើងនៅស្រុកខ្មែរយើង ដើម្បីកាត់ទោសមេដឹកនាំ ពីព្រោះធ្វើនៅស្រុកខ្មែរ?

យន់ ៖ កាត់ទោសមេដឹកនាំពីជំនាន់យើង។ ត្រង់នឹងដូចនិយាយម៉េច បើសិនថានៅតែធ្វើនៅតែឈឺចាប់តទៅទៀតចឹង។ ម៉្លេះហើយយើងត្រូវបំភ្លេចចោលខ្លះ ព្រោះម្នាក់ៗក្នុងមួយគ្រួសារមួយពោះ មួយខ្សែសារពីដូនតាមក។ ម្នាក់ៗសល់តែចឹង ៤, ៥, ៣, ៤បើសិនជារំលឹកឡើងវិញ ទៅវាចេះតែឈឺចាប់។

កុសល ៖ សុខចិត្តបំភ្លេចចោល?

យន់ ៖ ចា៎! អានឹងយើងត្រូវការប្រឆាំង ប្រាសាទព្រះវិហារយើងមកការពារ។

កុសល ៖ ចុះបងគិតម៉េច បើសិនជាគេថា បើសិនជាមិនមានការកាត់ទោសទេ ប្រទេសយើងមិនអាចផ្សះផ្សាបានទេ ដោយសារតែជនរងគ្រោះនៅតែមិនអស់ចិត្តនៅតែយំសោក នៅតែឈឺចាប់ បើកាត់ទោសដូចថាអ្នកត្រឹមតែមេធំៗ ប៉ុល ពត ស្លាប់ហើយ នៅខៀវ សំផន, ដែលជាប់គុកនៅនោះ នួន ជា,អី កាត់ទៅធ្វើឲ្យមានការរំសាយចិត្ត តើបងយល់យ៉ាងម៉េចដែរ? ទោះបីកាត់ទៅអត់មានបញ្ហា អត់មានរំសាយចិត្ត អត់មានជួយបងសប្បាយចិត្ត?

អ្នកជិតខាង៖អត់មានជួយសប្បាយចិត្តនៅតែភ័យខ្លាចនៅតែព្រួយបារម្ភ ព្រោះវាកន្លងហួសអស់ទៅហើយ។

កុសល ៖ ប៉ុន្តែខបមាថាគាត់ជាអ្នកធ្វើខុស ហេតុអីបានគាត់រួចខ្លួន?

អ្នកជិតខាង៖គាត់ខុសៗបានមួយជាប់គុក គាត់នៅនឹងទៅ។

កុសល ៖ ទេ! ឥឡូវគេអត់ទាន់សម្រេចទេ តែគ្រាន់ចាប់គាត់សួរ ដើម្បីដឹងពីការពិត។ តើមីងចង់ដឹងការពិត អ៊ីដែលកើតឡើងត្រង់នឹងទេ?

អ្នកជិតខាង៖ចង់ដឹងៗ។

កុសល ៖ បើចង់ដឹង បើមិនសួរគាត់ៗម៉េចដឹង។

អ្នកជិតខាង៖បើមិនកាត់ទោសម៉េចដឹង។

កុសល ៖ បាទ! ចឹងបានថា កាត់ទៅបានសួរ គាត់ឆ្លើយ។ ចុះបងយល់ម៉េចដែរចឹង?

អ្នកជិតខាង៖អានឹងចង់ដឹង។

កុសល ៖ បើចឹងដឹងទាល់តែតាមរយៈតុលាការនឹង គេអាចជួយបំភ្លឺឲ្យយើងដឹង។ ធ្វើម៉េចចុះ?

អ្នកជិតខាង៖នៅតែមិនរួច ឆ្លើយទៅឆ្លើយមកនៅតែមិនរួចកាត់ទោស។

កុសល ៖ ព្រោះគេចង់មិនចង់ គេកាត់ហើយឥឡូវនឹងមិនចឹង គេធ្វើចង់មិនចង់ ។ តែសំខាន់ យើងយល់ថាអានឹងវាល្អ ឬអត់ អ៊ីដែលខ្ញុំចង់ដឹង ។ រឿងគេធ្វើៗហើយ ខាងរដ្ឋាភិបាលកាត់តែមេធំ៣-៤នាក់នឹង ដើម្បីធ្វើយ៉ាងណា ដើម្បីបញ្ចប់ទៅរឿងនឹង ព្រោះគាត់យល់ថា បើមិនធ្វើចឹងទេ គឺវាមិនកើតទេ ព្រោះគាត់ជាមេដឹកនាំកំពូលជនាន់នឹង ។ ចំពោះអ្នកខាងក្រោមៗគ្នាគ្មានដឹងអីទេ អ្នកខាងលើ ។

យន់ ៖ ចា៎! អានឹងដូចលោកគ្រូសួរវិលចុះវិលឡើង អត់ដឹងដូចខ្ញុំអត់ដឹងមែន អត់ដឹងថារឿងមូលហេតុនឹងកើតមកពីអីអត់ដឹង ។

កុសល ៖ បាទ! ខ្ញុំចង់ដឹងការពិតដែរ តើកើតអីម៉េចខ្លះ ។

យន់ ៖ ខ្ញុំដឹងថាគេកាប់សម្លាប់ៗហើយ ខ្ញុំដឹងថាគេវ៉ៃហើយ ប៉ុនអត់ដឹងថាមូលហេតុពីលើមករបៀបម៉េច ខ្ញុំអត់ដឹងត្រង់នឹង ។

កុសល ៖ ចុះសំនួរចុងក្រោយ បងគិតថា ដើម្បីឲ្យមានការផ្សះផ្សាបាន យើងរៀនទប់កំហឹងក្នុងចិត្តទប់កំហឹងកុំឲ្យវាកើតឡើង ឈប់គិតពីរបបនឹងទៀត ។ គិតពីអីៗជំនួសវិញផ្សេង រឿងនឹងវាកន្លងផុតទៅហើយ ធ្វើបុណ្យបានបុណ្យធ្វើបានបុណ្យ ធ្វើបាបបានបាប?

យន់ ៖ ចា៎! អានឹងចឹងឯង ។

កុសល ៖ បងគិតថាការអត់ឱនទោសឲ្យគ្នាទៅវិញទៅមកសំខាន់ទេ ក្នុងរបបយើង?

អ្នកជិតខាង៖ក្នុងរបបសព្វថ្ងៃនឹង អត់ឱនទោសឲ្យគ្នាទៅវិញទៅមកជាសំខាន់ ។

កុសល ៖ ហេតុអី?

អ្នកជិតខាង៖ហេតុអី យើងចង់បានសេចក្តីសុខសងខាង ។

យន់ ៖ ហ៎ា! គ្រូសួរនេះ ដូចខ្ញុំឆ្ងល់សួរយើងរស់នៅក្នុងបច្ចុប្បន្ន ពី?

កុសល ៖ ទាំងអស់ពីអ៊ីពីមុនមក?

យន់ ៖ រួមពីជំនាន់នឹង?

កុសល ៖ បាទ! សង្គមយើងត្រូវការអត់ឱនទោស ទោះបីអ្នកជនរងគ្រោះនឹង មេជំនាន់៣ខែ(ឆ្នាំ) មានការកាប់សមាប់តើយើងគួរតែអត់ឱនទោសឲ្យគាត់ទេ?

យន់ ៖ អានឹងវាកន្លងមកហើយធ្វើអនុគ្រោះចឹង មិនដឹងគេធ្វើម៉េច ។

កុសល ៖ ពីរនឹងមួយណាល្អជាង ការអត់ឱនទោសឲ្យ ហើយនឹងការដាក់ទោសគាត់?

យន់ ៖ មានតែការអនុគ្រោះឲ្យ បើលោកគ្រូសួរពីសំនួរនឹង បើសិនយើងធ្វើចេះតែឃើញ បើយើងមិនធ្វើក៏វាស្ងាត់ ។

កុសល ៖ ខ្ញុំមានតែប៉ុននឹងអរគុណច្រើន ហើយសង្ឃឹមថាគេមិនមកយកដីយើងច្រើនទៀតចុះ ចាំខ្ញុំទៅ ។ ខ្ញុំចុះមកបេះ ខ្ញុំទៅលើវិញទៅរាយការណ៍ប្រាប់ថា មើលទៅមនកើតទេ ពួកក្រុមហ៊ុនអស់នេះ មកប៉ះពាល់ដល់ច្រើនណាស់ ។ ហើយរឿងការកាត់ទោសនៅភ្នំពេញក៏ចឹងដែរ ដូចថាអ្នកបរទេសបេះចង់ឲ្យបន្តៗទៅណា ។

«ចប់»